NEWS RELEASE

UNITED NATIONS HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

## សិទ្ធិមនុស្ស ជានិច្ចកាល ត្រូវតែបានការពារ
## សូម្បីតែនៅពេលប្រយុទ្ធប្រឆាំងនឹងភេរវកម្មក្តី - ជំនាញការ អ.ស.ប បានមានប្រសាសន៍

ទីក្រុងហ្សឺណែវ (១៦ មេសា ២០១៥) - សិទ្ធិ និងសេរីភាពរបស់មនុស្ស មិនគួរត្រូវបានបរិច្ចាគសម្រាប់តែភាពងាយស្រួលខាងនយោបាយក្នុងការប្រយុទ្ធប្រឆាំងនឹងភេរវកម្មឡើយ អ្នកជំនាញការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ពីររូប បានមានប្រសាសន៍ដូច្នេះ នៅថ្ងៃនេះ។

"មានតែការប្រកាន់ខ្ជាប់នូវបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិទេ ទើបអាចឲ្យយុទ្ធសាស្ត្រប្រឆាំងភេរវកម្មសម្រេចជោគជ័យនៅទីបំផុត" នេះបើតាមប្រសាសន៍របស់លោក បេន អ៊ីមមើរសិន (Ben Emmerson) អ្នករាយការណ៍ពិសេសស្តីពីការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ទន្ទឹមនឹងប្រយុទ្ធប្រឆាំងភេរវកម្ម និងលោក ហៃណឺ ប៊ីលេហ្វែលដ៍ (Heiner Bielefeldt) អ្នករាយការណ៍ពិសេសស្តីពីសេរីភាពខាងជំនឿ សាសនា។

"ទន្ទឹមនឹងយើងថ្កោលទោសយ៉ាងខ្លាំងក្លា ចំពោះអំពើភេរវកម្ម ជាពិសេសនៅពេលដែលសហគមន៍អន្តរជាតិបានអះអាងជាថ្មីនូវការប្តេជ្ញាចិត្តឥតងាករេ របស់ខ្លួន ក្នុងការប្រយុទ្ធប្រឆាំងនឹងភេរវកម្ម យើងក៏ត្រូវទាមទារឲ្យមានការគោរពសិទ្ធិមនុស្ស ក្នុងបរិបទនៃបញ្ហាប្រឈមមួយនេះដែរ" អ្នកជំនាញការមានប្រសាសន៍ដូច្នេះដោយតម្រង់មតិយោបល់របស់ខ្លួន ទៅរដ្ឋាភិបាលទាំងឡាយ ដែលបច្ចុប្បន្នកំពុងចូលរួមក្នុងយុទ្ធនាការប្រឆាំងភេរវកម្ម។

ជំនាញការសិទ្ធិមនុស្សបានពិពណ៌នាអំពីការវាយប្រហារកាលពីពេលថ្មីៗនេះនៅសាកលវិទ្យាល័យហ្គារីស្សា (Garissa University College) នៅប្រទេសកេនយ៉ា ដែលបានសម្លាប់និស្សិត និងសាស្ត្រាចារ្យយ៉ាងហោចណាស់ ១៤៧ នាក់ ថាជា "អំពើមួយដែលសាហាវព្រៃផ្សៃបំផុត" ដែល "បង្ហាញពីសេចក្តីត្រូវការបន្ទាន់មួយដើម្បីពិចារណាឡើងវិញ អំពីការឆ្លើយតបទៅនឹងការប្រយុទ្ធប្រឆាំងនឹងអំពើភេរវកម្ម ដោយផ្អែកតែលើការអនុវត្តច្បាប់ និងកម្លាំងយោធា"។

"អ្នកសង្កេតការណ៍ជាច្រើនលើអំពើហឹង្សាដូចនេះ តែងមានទំនោរទៅរកការមើលស្រាលចំពោះភាពស្មុគស្មាញនៃបាតុភូតទាំងនេះ ដោយប្រើពាក្យ "សាសនា" ជាទូទៅ និងដោយធូររលុង ទន្ទឹមនឹងវាក៏សំខាន់ផងដែរ ក្នុងការគិតឲ្យបានហ្មត់ចត់ថែមទៀត អំពីកត្តាដែលមិនមែនជាសាសនា" លោក បេន អ៊ីមមើរសិន និងលោក ហៃណឺ ប៊ីលេហ្វែលដ៍ បានមានប្រសាសន៍ដូច្នេះ។

"នេះគឺជាការពិតជាពិសេស នៅពេលជួបប្រទះបញ្ហាប្រឈមដូចជាជម្លោះប្រដាប់អាវុធ អភិបាលកិច្ចខ្សោយ ការធ្វើឲ្យខូចបរិស្ថាន អំពើពុករលួយដែលរាលដាល គេវ៉ើដំណែលប្រវត្តិសាស្ត្រស្មុគស្មាញនៃប្រទេសមួយ ដែលភាពក្រីក្របំផុត ការរើសអើងនយោបាយ សេដ្ឋកិច្ច វប្បធម៌ និងសង្គម ក៏ដូចជា ការមិនសូវគិតគូរអើពើ ដល់ប្រជាពលរដ្ឋផ្នែកធំមួយចំនួន ឬរយៈពេលអូសបន្លាយយូរនៃការដួលរលំរដ្ឋ" ជំនាញការបានគូសបញ្ជាក់ ដូច្នេះ។ "ករណីទាំងនេះ ផ្តល់ភាពងាយស្រួលសម្រាប់ការជ្រើសរើស ដល់សកម្មភាពទាំងឡាយណាដែល សន្យាថានឹងអាចមានការផ្លាស់ប្តូរ ប៉ុន្តែជ្រើសយកប្រើប្រាស់មធ្យោបាយនៃអំពើភេរវកម្មដែលមិនអាចទទួល យកបាន ដើម្បីសម្រេចគោលដៅរបស់ខ្លួនទៅវិញ"។

ជំនាញការបានគូសបញ្ជាក់ថា ទន្ទឹមនឹងមិនអាចមានការឆ្លើយតបតែមួយគត់ ចំពោះបញ្ហាទាំងនោះ វាច្បាស់ ណាស់ថា វិធីសាស្ត្រមួយប្រកបដោយនិរន្តរភាពគឺជាការចាំបាច់ ក្នុងការប្រយុទ្ធប្រឆាំងនឹងភេរវកម្ម ដែលដោះ ស្រាយ មិនត្រឹមតែការបង្ហាញពីអំពើភេរវកម្មយ៉ាងច្បាស់ប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវដឹងពីឫសគល់របស់វាផងដែរ។

រដ្ឋជាសមាជិករបស់ អ.ស.ប ទាំងអស់ បានទទួលស្គាល់ជាឯកច្ឆ័ន្ទថា ការការពារសិទ្ធិ និងសេរីភាពរបស់ មនុស្ស  គឺជាបុរេលក្ខខណ្ឌនៃយុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងនឹងភេរវកម្មយ៉ាងមានប្រសិទ្ធិភាព។ សេចក្តីសម្រេច ចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខ ឆ្នាំ១៩៦៣ ចែងថា ភេរវកម្មនឹងមិនអាចត្រូវបានយកឈ្នះបាន ដោយកម្លាំង យោធា វិធានការអនុវត្តច្បាប់ និងប្រតិបត្តិការស៊ើបការណ៍សម្ងាត់ តែប៉ុណ្ណឹងបានឡើយ។

"ដោយការលើកស្ទួយ និងការការពារសិទ្ធិមនុស្សយ៉ាងសកម្ម  រដ្ឋនានារួមចំណែកដល់ការទប់ស្កាត់អំពើភេរ វកម្មក្នុងកិច្ចខិតខំប្រឹងប្រែងមួយ ដើម្បីដោះស្រាយរកឫសគល់របស់ភេរវកម្មនេះ និងកត្តាហានិភ័យផ្សេងៗ" អ្នកជំនាញការបានមានប្រសាសន៍ដូច្នេះ ដោយកត់សម្គាល់ថា នេះគឺជាស្មារតីនៃយុទ្ធសាស្ត្រ ប្រឆាំងនឹងភេរ វកម្មពិភពលោករបស់ អ.ស.ប ដែលបានបញ្ជាក់ជាថ្មីកាលពីពេលថ្មីៗនេះ នៅឆ្នាំ២០១៤។ យុទ្ធសាស្ត្រនេះ សង្កត់ធ្ងន់ថា វិធានការណាមួយដែលបានអនុម័តដោយរដ្ឋនានា ដើម្បីប្រយុទ្ធប្រឆាំងនឹងភេរវកម្ម ត្រូវតែ គោរពតាមកាតព្វកិច្ចរបស់ខ្លួន ក្រោមច្បាប់អន្តរជាតិ ជាពិសេស សិទ្ធិមនុស្សអន្តរជាតិ សិទ្ធិជនភៀសខ្លួន និង ច្បាប់មនុស្សធម៌។

"នេះមិនមែនជាបញ្ហាតែមួយគត់ អំពីជម្នានុរូបភាពនោះទេ វាក៏ជាបញ្ហាអំពីការបង្ការប្រកបដោយប្រសិទ្ធភាព" អ្នកជំនាញឯករាជ្យបានមានប្រសាសន៍ដូច្នេះ។ "ការគោរពនីតិរដ្ឋ និងការការពារសិទ្ធិមនុស្ស និងសេរីភាពជា មូលដ្ឋាន គឺសំខាន់ចាំបាច់ក្នុងការផ្តល់ជម្រើសជោគជ័យមួយ បើមិនផ្តល់ជម្រើសនេះទេ អ្នកនោះអាចនឹង ងាយទទួលយកការជ្រើសរើសរបស់ភេរវករ និងចំពោះមូលវិវត្តកម្ម"។

អ្នកជំនាញ អ.ស.ប បានគូសបញ្ជាក់ថា យុទ្ធសាស្ត្រទាំងឡាយណាដែលរឹងមាំ មានលក្ខណៈទូលំទូលាយ

និងមាននិរន្តរភាព ក្នុងការប្រយុទ្ធប្រឆាំងនឹងភេរវកម្ម ក៏តម្រូវឲ្យមានការទទួលស្គាល់អំពីការឈឺចាប់របស់ជនរងគ្រោះនៃអំពើភេរវករផងដែរ។ រដ្ឋនានា គួរតែទទួលយកកាតព្វកិច្ចពិសេសនេះ ចំពោះជនរងគ្រោះនៃអំពើភេរវកម្ម សំដៅផ្តល់សំណងសមរម្យដល់ជនរងគ្រោះដោយអំពើភេរវកម្មទាំងអស់ ដែលកើតមាននៅលើទឹកដីរបស់ខ្លួន ដោយមិនគិតថាពួកគេជាមន្ត្រីសាធារណៈ ឬក៏មិនមែន ដែលត្រូវបានរកឃើញថាមានកំហុសត្រង់ចំណុចអ្វីមួយ។

ជំនាញការបានកត់សំគាល់ថា "វាមិនត្រឹមត្រូវ អយុត្តិធម៌ និងអមនុស្សធម៌ ដែលតម្រូវឲ្យជនរងគ្រោះ បង្ហាញភ័ស្តុតាងដាក់បន្ទុកអំពីកំហុសពីខាងអាជ្ញាធរសាធារណៈ កាលបើភស្តុតាងទាំងអស់ស្ថិតនៅក្នុងដៃរបស់រដ្ឋ ហើយភាគច្រើននៃភ័ស្តុតាងទាំងនោះ ត្រូវបានគេធ្វើចំណាត់ថ្នាក់រួចរាល់ហើយនោះ។"

"ការឈឺចាប់របស់ជនរងគ្រោះ មិនគួរត្រូវបានប្រើប្រាស់ខុស ដោយការយកធ្វើជាលេស ដើម្បីបដិសេធសិទ្ធិរបស់អ្នកដែលសង្ស័យពីអំពើភេរវកម្ម ដើម្បីបង្ហាញអំពីភាពត្រឹមត្រូវនៃវិធានការបន្ទាន់ រួមទាំងការប្រើប្រាស់អំណាចប្រតិបត្តិហួសហេតុ និងមិនសមាមាត្រ ការបង្ក្រាបសកម្មភាពប្រឆាំងដោយសន្តិវិធីស្របច្បាប់ ឬសម្រាប់គោលដៅនយោបាយរិតត្បិតដទៃផ្សេងទៀត" អ្នកជំនាញការបានបន្ថែមដូច្នេះ។

"នេះបន្ថែមទៅលើវង្វង់ដ៏កាចសាហាវ នៃអំពើភេរវកម្ម ដោយរួមចំណែកដល់ការធ្វើឲ្យបាត់ភាពជាមនុស្សនៃជនរងគ្រោះដោយអំពើភេរវកម្ម" ជំនាញការបានកត់សំគាល់ដូច្នេះ។ "ការគោរពពិតប្រាកដ ចំពោះមនុស្សជាតិនៃជនរងគ្រោះ តម្រូវថា ការការពារសិទ្ធិមនុស្សមិនត្រូវឲ្យមានការកាត់បន្ថយសិទ្ធិមនុស្សឡើយ" អ្នកជំនាញការឯករាជ្យបានមានប្រសាសន៍ដូច្នេះ ដោយផ្តល់ជាអនុសាសន៍ថា រដ្ឋទាំងឡាយឈានទៅរកការអនុម័តលិខិតុបករណ៍អន្តរជាតិជាក់លាក់មួយ ដែលចែងអំពីសិទ្ធិរបស់ជនរងគ្រោះនៃអំពើភេរវកម្ម និងកាតព្វកិច្ចពាក់ព័ន្ធរបស់រដ្ឋទាំងនោះ។

**ចប់**

*អ្នកជំនាញការឯករាជ្យគឺជាផ្នែកមួយនៃអ្វីដែលគេស្គាល់ថាជានីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ នីតិវិធីពិសេស (ស្ថាប័នដ៏ធំបំផុតមួយនៃអ្នកជំនាញការឯករាជ្យនៅក្នុងប្រព័ន្ធអង្គការសហប្រជាជាតិ) គឺជាឈ្មោះទូទៅនៃយន្តការឃ្លាំមើលនិងស្វែងរកការពិតឯករាជ្យរបស់ក្រុមប្រឹក្សានេះ ដែលលើកអំពីស្ថានភាពរបស់ប្រទេសមួយជាក់លាក់ ឬតាមវិស័យនីមួយៗនៅគ្រប់តំបន់ទាំងអស់នៃពិភពលោក។ អ្នកជំនាញការរបស់នីតិវិធីពិសេស ធ្វើការឈរលើគោលការណ៍ស្ម័គ្រចិត្ត ពួកគាត់មិនមែនជាបុគ្គលិក អ.ស.ប ទេ ហើយក៏មិនទទួលប្រាក់បៀវត្សរ៍សម្រាប់ការងាររបស់ពួកគាត់ដែរ។ ពួកគាត់ធ្វើការឯករាជ្យពីរដ្ឋាភិបាល ឬអង្គការណាមួយ ហើយបំរើការក្នុងសមត្ថភាពបុគ្គលផ្ទាល់របស់ពួកគាត់។*

*http://www.ohchr.org/EN/HRBodies/SP/Pages/Welcomepage.aspx*

*ដើម្បីមើលយុទ្ធសាស្ត្រសកលប្រឆាំងនឹងភេរវកម្មរបស់ អ.ស.ប ឆ្នាំ២០០៦ ៖*
*http://www.un.org/terrorism/strategy-counter-terrorism.shtml*

*ដើម្បីអានរបាយការណ៍ស្តីពីការបង្ការអំពើហិង្សាដែលបានប្រព្រឹត្តដោយប្រើឈ្មោះសាសនា ដែលបានចងក្រងដោយអ្នករាយការណ៍ពិសេសស្តីពីសេរីភាពខាងជំនឿសាសនា (A/HRC/28/66)៖*
*http://www.ohchr.org/EN/HRBodies/HRC/RegularSessions/Session28/Pages/ListReports.aspx*

*សម្រាប់ព័ត៌មានបន្ថែម និង**សំណើព័ត៌មាន** សូមទាក់ទងមក ៖ អាលេស្សាន់ដ្រូ ម៉ារ៉ា (Alessandro Marra) តាមរយៈ ទូរស័ព្ទលេខ (+៤១ ២២ ៩២៨ ៩៨៧០ / អ៊ីមែល amarra@ohchr.org) ឬសរសេរទៅកាន់ srct@ohchr.org.*

សម្រាប់**ការសាកសួរព័ត៌មាន**ពាក់ព័ន្ធនឹងអ្នកជំនាញការឯករាជ្យដទៃទៀតរបស់ អ.ស.ប សូមមេត្តាទាក់ទងមក ឈ្មោះ សាប៉ៀ ស៊ីលាយ៉ា (Xabier Celaya) សិទ្ធិមនុស្ស អ.ស.ប – អង្គភាពព័ត៌មាន តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩៣៨៣ / អ៊ីមែល xcelaya@ohchr.org)

**សិទ្ធិមនុស្ស អ.ស.ប ស្វែងយល់ពីយើង លើបណ្តាញព័ត៌មានសង្គម ៖**

**ហ្វេសប៊ុក៖** https://www.facebook.com/unitednationshumanrights
**ទ្វីតធឺ៖** http://twitter.com/UNrightswire
**ហ្គោហ្គ៍ល៖ Google+** gplus.to/unitednationshumanrights
**យូធូប៖** http://www.youtube.com/UNOHCHR

**ឆែកមើលលិបិក្រមសិទ្ធិមនុស្សជាសកល៖** http://uhri.ohchr.org/en